## ជំពូកទី ៤

# ស្វែងរកឱ្យឃើញនូវអ្វីៗដែល កូនអ្នកអាចមើលឃើញ

កុមារ**ជាច្រើន**ដែលលំបាកក្នុងការមើលឃើញ គឺមិនងងឹតភ្នែកសូន្យឈឹងឡើយ តែអាចមើលឃើញតិចតួច ។ កុមារមួយចំនួនអាចមើលឃើញភាពខុសគ្នារវាងកន្លែងងងឹត និងកន្លែងភ្លឺ តែមិនអាចមើលឃើញវត្ថុអ្វីមួយឡើយ ។ កុមារខ្លះទៀតអាចមើលឃើញវត្ថុ បើសិនជាពួកគេស្ថិតនៅកន្លែងណាមួយច្បាស់លាស់ មានពន្លឺច្បាស់ល្អ ឬ បើសិនជាវត្ថុទាំងនោះមានទំហំជាក់លាក់ ឬក៏មានពណ៌ភ្លឺច្បាស់ ។ កុមារខ្លះទៀតអាចមើលឃើញចលនា ។

មុនពេលចាប់ផ្តើមសកម្មភាពទាំងឡាយនៅក្នុងសៀវភៅនេះ វាគឺជាការសំខាន់ក្នុងការស្វែងរកឱ្យឃើញអ្វីដែលកូនអាចមើលឃើញ ។ ការដឹងអំពីករណីទាំងនេះនឹងជួយអ្នកឱ្យធ្វើសកម្មភាពទៅតាមវិធីដែល**ភាគច្រើនជួយឱ្យកូនរៀនសូត្របានល្អ ។**

បើសិនជាកូនអ្នកអាចមើលឃើញតិចតួច ការដឹងរបៀបដែលកូនមើលឃើញល្អបំផុត ក៏មានន័យថាអ្នកអាចជ្រើសរើសសកម្មភាពទាំងឡាយដែលនឹងជួយកូនឱ្យចេះប្រើ**គំហើញដែលនៅសេសសល់បានស្ទើរតែទាំងអស់ ។**




**ការប្រើគំហើញមិនធ្វើឱ្យឈានទៅរកការបាត់បង់វាឡើយ។**
**ភ្នែករបស់កូនអ្នកនឹងមិនឈឺចាប់ បើនាងប្រើវាដើម្បីជួយខ្លួនឯងធ្វើអ្វីៗ។**

## តើកូនខ្ញុំពិការភ្នែកសុន្យឈឹង ឬ គេអាចមើលឃើញតិចតួចដែរ?

បើអ្នកមិនប្រាកដក្នុងចិត្តថាកូនអាចនៅមើលឃើញខ្លះៗនោះ ចូរសង្កេតមើលដើម្បីឱ្យឃើញ :-

តើនាងបិទភ្នែកនៅក្រោមពន្លឺចែងចាំងនៃព្រះអាទិត្យ ឬក៏នាងងាកក្បាលឆ្ពោះទៅរកពន្លឺ?



តើនាងយកវត្ថុមកដាក់ជិតភ្នែកខ្លួនឯងឬទេ?



តើនាងងាកក្បាលតាមវត្ថុដែលកំពុងបំលាស់ទីយឺតៗឬទេ?



តើនាងតែងតែផ្អៀងក្បាលតាមរបៀបណាមួយច្បាស់លាស់ឬទេ?



តើនាងគ្រវីដៃចុះឡើងទៅមកនៅពីមុខភ្នែកខ្លួនឯងឬទេ?



តើនាងឈោងដៃចាប់វត្ថុដែលមិនបន្លឺសម្លេងឬទេ?



បើសិនជាអ្នកសំគាល់ឃើញករណីណាមួយនៃទង្វើទាំងនេះ  អ្នកអាចរៀនថែមទៀតអំពីន័យរបស់ទង្វើទាំងនោះ ដោយការអានពីរ-បីទំព័រខាងមុខទៀត។

## តើកូនខ្ញុំមើលឃើញអ្វីនៅ?

### តើពន្លឺប្រភេទណាដែលជួយកូនខ្ញុំឱ្យមើលឃើញល្អបំផុត?

កុមារមួយចំនួនប្រហែលមានបញ្ហាក្នុងការបន្សាំខ្លួនចំពោះការផ្លាស់ប្តូរកំរិតនៃពន្លឺ ។ ឬក៏កូនអ្នកប្រហែលជាអាចមើលឃើញនៅក្នុងប្រភេទនៃពន្លឺមួយចំនួន  តែមិនអាចមើលឃើញចំពោះពន្លឺមួយចំនួនទៀត ។

ចូរសំគាល់មើល បើសិនជាកូនអ្នកមើលដោយបើកភ្នែកព្រឹមៗ ឬ ងាកចេញពីពន្លឺភ្លើង ។ នាងប្រហែលជាអាចមើលឃើញល្អបំផុតនៅពេលពន្លឺភ្លើងមិនសូវចាំងខ្លាំងពេក ឬក៏ពេលអាកាសធាតុមានពពកមីដេរដាស ។

ចូរសំគាល់មើល បើសិនជាកូនអ្នកចូលចិត្តមើលទៅអ្វីៗនៅកន្លែងមានពន្លឺ ។ នាងប្រហែលជាអាចមើលឃើញបានល្អបំផុតនៅក្នុងបន្ទប់មានពន្លឺខ្លាំង ឬនៅក្រោមពន្លឺព្រះអាទិត្យកំពុងបញ្ចេញរស្មីខ្លាំង ។





ទិសដៅដែលពន្លឺចេញមកអាចធ្វើឱ្យប៉ះពាល់ដល់អ្វីដែលកូនអ្នកអាចមើលឃើញ ។  ចូរព្យាយាមផ្លាស់ប្តូរស្ថានភាពពន្លឺ  ខណៈដែលនាងធ្វើកិច្ចការខុសៗគ្នាដើម្បីរកឱ្យឃើញនូវអ្វីដែលអាចជួយនាងបានល្អបំផុត ។



**ដើម្បីមើលឃើញភាពលំអិត  ក្មេងនេះមើលឃើញល្អបំផុតនៅពេលពន្លឺភ្លើងចាំងចំពីលើវត្ថុ។**



ប្រភេទនៃពន្លឺក៏អាចធ្វើឱ្យមានភាពខុសគ្នាផងដែរ ។    កុមារខ្លះធ្វើបានល្អជាមួយពន្លឺផ្តោតលើអ្វីដែលគេមើលឃើញ ។ កុមារខ្លះទៀតធ្វើបានល្អជាមួយពន្លឺភ្លើងបាចសាច តែពន្លឺនៅតែចាំងខ្លាំង ។

## ចម្ងាយត្រឹមណាដែលកូនខ្ញុំមើលឃើញល្អបំផុត?

កុមារភាគច្រើនដែលអាចមើលឃើញតិចតួច មើលឃើញវត្ថុល្អបំផុតនៅចម្ងាយប្រវែងមួយបោះដៃផុត ។ ប៉ុន្តែកុមារខ្លះមើលឃើញវត្ថុល្អបំផុតនៅយ៉ាងជិតមុខរបស់ខ្លួន ។ កុមារខ្លះទៀតមើលឃើញល្អបំផុត នៅពេលដែលវត្ថុស្ថិតនៅយ៉ាងឆ្ងាយ ។ ចូរសង្កេតមើលកូនអ្នកដោយប្រុងប្រយ័ត្នដើម្បីឱ្យឃើញថា ចម្ងាយប្រវែងណាដែលនាងពេញចិត្តកាន់វត្ថុនៅពីមុខខ្លួនឯង ។ នេះប្រហែលជាចម្ងាយដែលនាងមើលឃើញល្អបំផុតហើយ ។



ក្មេងនេះមើលឃើញវត្ថុល្អបំផុតនៅចម្ងាយមួយបោះដៃផុត...



...តែក្មេងនេះមើលឃើញវត្ថុល្អបំផុតនៅយ៉ាងជិតមុខរបស់ខ្លួន

## នៅក្នុងទិសដៅណាដែលកូនខ្ញុំមើលឃើញល្អបំផុត?

កុមារស្ទើរតែទាំងអស់មើលឃើញវត្ថុដែលនៅចំពីមុខពួកគេផ្ទាល់យ៉ាងច្បាស់ក្រឡែត ពួកគេក៏អាចមើលឃើញវត្ថុដែលនៅចំហៀងណាមួយ ឬ នៅខាងលើ ឬ ខាងក្រោមភ្នែករបស់គេបានដែរ ។ ទោះជាយ៉ាងណាក៏ដោយ ជួនកាលកុមារមិនអាចមើលឃើញយ៉ាងឆ្ងាយទៅចំហៀងឡើយ ។ ឬ នាងមិនអាចមើលឃើញទាំងស្រុងនៅគ្រប់កន្លែងដូចជា នៅតំបន់ចំពីមុខខ្លួននាង នៅចំណោមចំហៀងខ្លួនខាងណាមួយ ឬ ខាងក្រោមចង្ការនាង ឬ ខាងលើភ្នែកនាង ។ ដើម្បីស្វែងរឱ្យឃើញទិសដៅណាដែលកូនអ្នកមើលឃើញល្អបំផុត ចូរសង្កេតមើលនាងឱ្យបានជិតដល់ ដើម្បីឱ្យឃើញកន្លែងណាដែលនាងពេញចិត្តកាន់វត្ថុ ឬក៏របៀបដែលនាងងាកក្បាលមើលទៅវត្ថុមួយ ។



ក្មេងនេះអាចមើលឃើញវត្ថុដែលស្ថិតនៅចំហៀងខ្លួនតែប៉ុណ្ណោះ ដើម្បីមើលឃើញវត្ថុមួយ នាងត្រូវតែងាកក្បាលទៅចំហៀង ហើយមើលត្រឡប់ទៅវត្ថុនោះ។

## តើវត្ថុធំហំប៉ុណ្ណាដែលកូនខ្ញុំមើលឃើញល្អបំផុត?

កុមារស្ទើរតែទាំងអស់ដែលនៅមើលឃើញតិចតួច មើលឃើញវត្ថុធំៗបានល្អបំផុត ។ ប៉ុន្តែកុមារខ្លះអាចមើលឃើញផ្នែកតូចមួយនៅចំពីមុខគេតែប៉ុណ្ណោះ ។ កុមារទាំងនេះនឹងស្គាល់វត្ថុតូចៗងាយស្រួលជាងវត្ថុធំៗ ។ ចូរសង្កេតមើលកូនអ្នក ដើម្បីឱ្យឃើញថាវត្ថុទំហំប៉ុណ្ណាដែលនាងចូលចិត្តកាន់លេងជាមួយ ។



**ក្មេងនេះចូលចិត្តលេងជាមួយវត្ថុតូចៗពីព្រោះនាងមើលឃើញវាល្អបំផុត។**



**ក្មេងនេះមើលឃើញវត្ថុធំៗបានល្អបំផុត។**

## តើកូនខ្ញុំដឹងថាវត្ថុនៅឆ្ងាយប៉ុណ្ណាទេ?

កុមារខ្លះមានការលំបាកក្នុងការកំណត់ចម្ងាយវត្ថុថាវានៅឆ្ងាយប៉ុណ្ណា ។ ដូច្នេះនៅពេលដែលពួកគេឈោងយកវត្ថុ គេអាចឈោងឆ្ងាយហួសវត្ថុ ។ ឬក៏គេឈោងមិនល្មមនឹងចម្ងាយវត្ថុនោះ ពីព្រោះគេគិតថាវត្ថុនោះនៅជិតជាងទីតាំងពិតប្រាកដ ។ ដើម្បីរកឱ្យឃើញថាកូនអ្នកអាចស្មានពីចម្ងាយបានត្រឹមត្រូវឬទេ ចូរសង្កេតមើលពេលនាងឈោងយកប្រដាប់លេង ឬ វត្ថុផ្សេងទៀត ។



**ក្មេងនេះគិតថា ដបនោះនៅឆ្ងាយជាងទីតាំងពិតប្រាកដរបស់វា។**



**ក្មេងនេះចូលចិត្តលេងជាមួយឆ្នាំងដែលមានពណ៌ចាស់ ព្រោះនាងមើលឃើញវាច្បាស់ល្អជាងពណ៌របស់ស្លាបព្រា។**

## តើកូនខ្ញុំចូលចិត្តពណ៌ដិតច្បាស់ ឬក៏ពណ៌ខុសគ្នា (ផ្ទុយគ្នា) រវាងពណ៌ដិតច្បាស់ និងព្រាលឆ្អាស់គ្នា?

កុមារមួយចំនួនអាចមើលឃើញវត្ថុនៅពេលវាមានពណ៌ភ្លឺច្បាស់ ឬ ពេលវានៅទន្ទឹមនឹងវត្ថុមួយទៀតដែលមានផ្ទៃពណ៌ខុសគ្នា ។ ចូរសង្កេតមើលបើសិនជាកូនអ្នកនិយមពណ៌ភ្លឺច្បាស់, ពណ៌ខុសៗគ្នា ឬ ពណ៌ក្រឡេក្រឡាចម្រុះគ្នា ។ ទាំងនេះប្រហែលជាពណ៌ និងលំនាំដែលនាងទំនងជាអាចមើលឃើញបានល្អបំផុត ។

## តើមានអ្វីផ្សេងទៀតដែលធ្វើឱ្យប៉ះពាល់គំហើញរបស់កូនខ្ញុំ?

ជារឿយៗកុមារទំនងជាមើលឃើញបានល្អប្រសើរនៅពេលខ្លះ ជាងពេលខ្លះទៀត។ នេះមិនមានន័យថាគំហើញរបស់នាងបានផ្លាស់ប្តូរឡើយ តែមានអ្វីក្រៅពីនោះទៀតដែលកំពុងមានឥទ្ធិពលលើបរិមាណដែលនាងមើលឃើញ ដូចជា :-

- ថាតើវត្ថុមួយនោះនាងស៊ាំជាមួយវា ឬ នាងធ្លាប់ឃើញវា ឬ ធ្លាប់ប៉ះវាញឹកញាប់ប៉ុណ្ណា។
- ថាតើនាងនឿយហត់យ៉ាងណា។
- សុខភាពរបស់នាងយ៉ាងណា។
- ថាតើនាងកំពុងប្រើថ្នាំពេទ្យឬយ៉ាងណា។
- ថាតើនាងមានអារម្មណ៍សប្បាយ ឬក៏សោកសៅក្នុងចិត្ត។

អ្នកប្រហែលជាត្រូវសង្កេតមើលកូនដោយប្រុងប្រយ័ត្ននៅក្នុងស្ថានភាពខុសៗគ្នា និងពេលវេលាខុសពីគ្នាដើម្បីស្វែងរកឱ្យឃើញអំពីអ្វីដែលនាងអាចមើលឃើញពិតប្រាកដ។

## ជួយកូនឱ្យចេះប្រើគំហើញដែលនៅសេសសល់

បើសិនជាកូនអ្នកអាចមើលឃើញបន្តិចបន្តួច :-

សូមយកវត្ថុខុសៗគ្នាជាច្រើនឱ្យកូនមើល។ ប្រការនេះជួយលើកទឹកចិត្តនាងឱ្យចាប់អារម្មណ៍ពីព្រឹត្តិការណ៍នៅជុំវិញខ្លួននាង និងឱ្យនាងប្រើគំហើញកាន់តែច្រើនឡើង។





វិធីមួយក្នុងការបង្ហាញនាងអំពីវត្ថុផ្សេងៗគ្នា គឺនាំនាងដើរជុំវិញផ្ទះ។ ចូរនិយាយអំពីអ្វីដែលអ្នកមើលឃើញ ហើយលើកទឹកចិត្តនាងឱ្យស្ទាប និងកាន់របស់ទាំងនោះ។

ឱ្យកូនកាន់របស់របរ ឬ បែរខ្លួនទៅតាមរបៀបណាមួយដែលជួយឱ្យនាងមើលឃើញបានល្អបំផុត ទោះបីជាមើលទៅវាឆ្គងចំពោះអ្នកក៏ដោយ ។ ឧទាហរណ៍ :-



បើសិនជាកូនអ្នកមើលឃើញតែមួយជ្រុងតូចនៅពីមុខនាង នាងនឹងមើលឃើញកាន់តែច្រើន បើសិនជានាងមើលទៅលើ, មើលចុះក្រោម, ទៅស្តាំ និងទៅឆ្វេងក្នុងខណៈដែលនាងធ្វើបំលាស់ទី (ដើរ) ជាជាងមើលតែត្រង់ទៅមុខ ។

បើសិនជាកូនអ្នកអាចមើលឃើញបានតិចតួច ចូរព្យាយាមប្តូរកំរិតនៃពន្លឺ, ប្រភេទនៃពន្លឺ ឬ ទិសដែលពន្លឺជះចេញមក ។ ចូរពិនិត្យមើលអ្វីដែលមានដំណើរការល្អ ។





បើសិនជានាងមានបញ្ហាក្នុងការមើលឃើញនៅពេលដែលកំរិតនៃពន្លឺផ្លាស់ប្តូរ ចូរបង្រៀននាងឱ្យឈប់ដើរមួយសន្ទុះ ហើយរង់ចាំឱ្យភ្នែករបស់នាងបានស៊ាំនឹងពន្លឺសិន ។

ចូរសម្គាល់មើល ថាតើកូនអ្នកតែងផ្តោតយកចិត្តទុកដាក់ចំពោះអ្វីមួយច្បាស់លាស់ :-

- ពណ៌
- ផ្ទៃដែលមានពណ៌ចំរុះ
- ទំហំ
- ពណ៌ផ្ទុយគ្នា

បើសិនជានាងធ្វើបែបនោះមែន អ្នកអាចប្រើចំណង់ចំណូលចិត្តទាំងនេះដើម្បីឱ្យនាងរៀន និងធ្វើចលនាបំលាស់ទីតាំងដោយសុវត្ថិភាព។



**ដើម្បីទាក់ទាញចំណាប់អារម្មណ៍ទារករបស់គាត់ ម្តាយម្នាក់នេះរមៀលបាល់ពណ៌ងិតច្បាស់មួយ កាត់លើកំណាត់ពណ៌សមួយផ្ទាំង។**



**ចូរប្រើពណ៌ងិតច្បាស់ដើម្បីគូសជាយ ឬ គូសជុំវិញវត្ថុ ឬ ទីកន្លែង។ ប្រការនេះនឹងជួយឱ្យនាងរៀនស្គាល់កន្លែង និងទ្រង់ទ្រាយ។**

នៅពេលនាងធំបន្តិច ខ្សែបូរដែលមានពណ៌ភ្លឺច្បាស់, កំណាត់ ឬ វត្ថុអាចជួយនាងឱ្យស្គាល់ថា នាងនៅទីកន្លែងណា។






**បិទស្កុត ឬ លាបថ្នាំដែលមានពណ៌ភ្លឺច្បាស់ពីលើកាំជណ្តើរ ឬ កម្រាលផ្ទះ អាចជួយកុមារឱ្យដឹងអំពីការផ្លាស់ប្តូរកំពស់ខ្ពស់ ឬ ទាប។**

## តើគំហើញរបស់កូនខ្ញុំនឹងកាន់តែធ្ងន់ធ្ងរទៅឬទេ?

ដើម្បីឆ្លើយនឹងចម្លើយនេះ អ្នកត្រូវការដឹងពីហេតុផលដែលបណ្តាលឱ្យកូនអ្នកពិបាកមើលឃើញ។ ចំពោះព័ត៌មានបន្ថែមសូមអានជំពូកទី 16 "ហេតុអ្វីកុមារបាត់បង់គំហើញ និងអ្វីៗដែលយើងអាចធ្វើបាន" នៅទំព័រ 155។